C26/I/24

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 23 / 04 / 2008
ម៉ោង (Time/Heure): 08 : 50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**សំណុំរឿងព្រហ្មទណ្ឌ**

លេខ:00២/១៩-0៩-២00៧-អវតក-កសចស(អបជ0៤)

# <u>របាយការណ៍ស្តីពីការត្រួតពិនិត្យសំណុំរឿង (ឯកសារសាធារណៈ)</u>

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certifified Date/Date de certification): 23 / 04 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

I) **នីតិវិធី**

II) **ការពិនិត្យសំណុំរឿងដោយសហចៅក្រមរបាយការណ៍**

---

## I) នីតិវិធី

### ក) សេចក្តីផ្តើម

អនុលោមតាមវិធាន ៧៧(១០) នៃវិធានផ្ទៃក្នុងរបស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ("វិធានផ្ទៃក្នុង") ប្រធានអង្គបុរេជំនុំជម្រះបានចាត់តាំងលោកចៅក្រម **ហួត វុទ្ធី** និង លោកចៅក្រម **Rowan Downing** ឲ្យធ្វើរបាយការណ៍បង្ហាញពីអង្គហេតុ និង អង្គច្បាប់ អំពីសេចក្តីសម្រេចរបស់សហចៅក្រមស៊ើបអង្កេតក្នុងការចេញដីកាឃុំខ្លួនដែលត្រូវបានប្តឹងឧទ្ធរណ៍ និងធ្វើការត្រួតពិនិត្យលើសំណុំរឿង លេខ:00២/១៩-0៩-២00៧-អវតក-កសចស(អបជ0៤) ។

**ដែលក្នុងនោះជនត្រូវចោទ÷**

**ខៀវ សំផន** ហៅ " **ហែម** " ភេទប្រុស កើតថ្ងៃទី២៧ ខែកក្កដា ឆ្នាំ១៩៣១ នៅឃុំរំចេក ស្រុករំដួល ខេត្តស្វាយរៀង ប្រទេសកម្ពុជា សញ្ជាតិ ខ្មែរ ទីលំនៅមុនពេលចាប់ខ្លួន នៅភូមិកូនខ្ទង់ សង្កាត់អូរតាវៅ ខណ្ឌប៉ៃលិន ក្រុងប៉ៃលិន ឪពុកឈ្មោះ **ខៀវ ឡុង** (ស្លាប់) ម្តាយឈ្មោះ **ប៉ោ គង់** (ស្លាប់) ប្រពន្ធឈ្មោះ សូ សុជាតិ មានកូន ៤ នាក់។

តំណាងដោយសហមេធាវីការពារក្តី លោក **សាយ បូរី** និង លោក **Jacques Vergès** ។

# បទចោទប្រកាន់

**ខៀវ សំផន** ស្ថិតក្រោមការចោទប្រកាន់ពីបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ( អំពើឃាតកម្ម ការសម្លាប់បំផុតពូជ ការដាក់ឃុំឃាំង ការធ្វើទុកបុកម្នេញ និង អំពើអមនុស្សជាតិផ្សេងៗទៀត ) និងរំលោភបំពានលើអនុសញ្ញា ក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ( ការសម្លាប់ដោយចេតនា ការបង្កព្យសនកម្មធ្ងន់ធ្ងរ ការធ្វើឲ្យឈឺចាប់ខ្លាំងដោយចេតនាដល់រាងកាយ ឬ សុខភាព ការដកហូតដោយចេតនាពីអ្នកទោសសង្គ្រាម ឬ ជនស៊ីវិល នូវសិទ្ធិទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ ដែលជាបទល្មើសមានចែង និង ផ្តន្ទាទោស តាមមាត្រា ៥, ៦, ២៩ (ថ្មី) និង ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ ២០០៤ (ច្បាប់ អ.វ.ត.ក) ។

ចំពោះការដែលជននេះបានប្រព្រឹត្តនៅលើទឹកដីនៃប្រទេសកម្ពុជា រវាងថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ ៦ ខែមករា ឆ្នាំ១៩៧៩:

- ក្នុងឋានៈជាប្រមុខរដ្ឋ (ប្រធានគណៈប្រធានរដ្ឋ) ជាកម្មាភិបាលដឹកនាំនៅក្នុងការិយាល័យនយោបាយមជ្ឈិម (មន្ទីរលេខ ៨៧០) និងជាសមាជិកពេញសិទ្ធិនៃគណៈកម្មាធិការមជ្ឈិមនៃបក្សកុម្មុយនីស្តកម្ពុជា ។
- បានញុះញុង និងសមគំនិត ក្នុងការប្រព្រឹត្តនូវបទល្មើសទាំងឡាយខាងលើ ។
- ដោយដឹកនាំ លើកទឹកចិត្ត ដាក់ឲ្យអនុវត្ត ឬ ដោយផ្តល់ជំនួយ ក្រោមរូបភាពផ្សេងៗដទៃទៀតដល់គោលនយោបាយ និងការអនុវត្តរបស់បក្សនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលមានលក្ខណៈជាការធ្វើមនុស្សឃាត ការសម្លាប់បំផុតពូជ ការចាប់ដាក់ក្នុងមន្ទីឃុំឃាំង ការធ្វើទុក្ខបុកម្នេញដោយហេតុផលនយោបាយ ឬអំពើអមនុស្សធម៌ដទៃទៀតដូចជា ការជម្លៀសប្រជាជនដោយបង្ខំ ការដាក់ជាទាសករ ឬ ការដាក់ឲ្យធ្វើការងារដោយបង្ខំ ។
- នៅក្នុងក្របខ័ណ្ឌនៃការវាយប្រហារជាប្រព័ន្ធ និងជាទូទៅ សំដៅលើប្រជាជនស៊ីវិល ។
- ដោយបញ្ជាក់ថា ក្នុងកំឡុងពេលទាំងអស់ ឬមួយផ្នែកនៃរវាងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៩៧៥ និង ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩[1] កម្ពុជាប្រជាធិបតេយ្យ និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ស្ថិតនៅក្នុងស្ថានភាពនៃជំលោះប្រដាប់អាវុធអន្តរជាតិជាមួយគ្នា ។

---

[1] កំណត់ហេតុនៃការចូលខ្លួនដំបូង, ១៩ វិច្ឆិកា ២០០៧, D42 ទំព័រ ៣

## គោលបំណងនៃរបាយការណ៍

របាយការណ៍របស់សហចៅក្រមរបាយការណ៍នេះ សរសេរជាពិស្តារអំពីសេចក្តីសម្រេចដែលត្រូវបានប្តឹងឧទ្ធរណ៍ និងអង្គហេតុផ្សេងៗទៀតចំពោះមុខតុលាការ ។ របាយការណ៍នេះជួយផងដែរដល់អ្នកដែលមិនមែនជាភាគីក្នុងនីតិវិធីឱ្យយល់អំពីបញ្ហានៅចំពោះមុខតុលាការ ។

## ខ) ការស្នើសុំរបស់សហព្រះរាជអាជ្ញាសម្រាប់ការឃុំខ្លួនបណ្តោះអាសន្ន

នៅថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ២០០៧ សហព្រះរាជអាជ្ញា នៃ អ.វ.ត.ក បានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដែលក្នុងនោះស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតបើកការស៊ើបអង្កេតប្រឆាំងនឹងជនសង្ស័យមួយចំនួន រួមមាន ទាំង **ខៀវ សំផន** ផងដែរ និងស្នើសុំឱ្យធ្វើការចាប់ខ្លួន និងឃុំខ្លួនជនសង្ស័យទាំងនោះ[2] ។

សហព្រះរាជអាជ្ញាបានស្នើឱ្យមានការឃុំខ្លួន **ខៀវ សំផន** ជាបណ្តោះអាសន្នដោយផ្អែកលើសំអាងថាមានមូលហេតុគ្រប់គ្រាន់ដោយជឿជាក់ថាជននេះមានជាប់ពិរុទ្ធក្នុងបទល្មើសខាងលើ ហើយការឃុំខ្លួនជាការចាំបាច់ក្នុងការការពារការគាបសង្កត់លើសាក្សី ការធានាពីវត្តមានរបស់ជនត្រូវចោទក្នុងពេលសវនាការ ការការពារសុវត្ថិភាពផ្ទាល់ខ្លួនរបស់ជនត្រូវចោទ ក៏ដូចជាការធានានូវសណ្តាប់ធ្នាប់សាធារណៈ[3] ។

## គ). ដីកាឃុំខ្លួនចេញដោយសហចៅក្រមស៊ើបអង្កេត

នៅថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេត អ.វ.ត.ក បានចេញដីកានាំខ្លួនជនត្រូវចោទ **ខៀវ សំផន** មកចំពោះមុខតុលាការ[4] ។ នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០០៧ **ខៀវ សំផន** ត្រូវបានចាប់ខ្លួន និងនាំខ្លួនមកចំពោះមុខសហចៅក្រមស៊ើបអង្កេត សម្រាប់ការបង្ហាញខ្លួនលើកដំបូងរបស់គាត់[5] ។ **ខៀវ សំផន** យល់ព្រមឱ្យធ្វើការ ពិភាក្សាដេញ ដោលភ្លាមៗ ប៉ុន្តែស្នើសុំពេលពិភាក្សាជាមួយមេធាវីជាមុនសិន ។ នៅថ្ងៃទី ១៩ ខែ វិច្ឆិកា ឆ្នាំ២០០៧ សវនាការតទល់គ្នាត្រូវបានធ្វើឡើង[6] ហើយសហចៅក្រមស៊ើបអង្កេតបានចេញដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ដែលមានរយៈពេលកំណត់មិនលើសពី ១ឆ្នាំ[7] ។

## អង្គហេតុ និងអង្គច្បាប់ដែលបានលើកឡើងក្នុងដីកាសម្រេច

---

[2] សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, ១៨ កក្កដា ២០០៧, កថាខណ្ឌ ១២៤

[3] សេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ, កថាខណ្ឌ ១១៨

[4] ដីកាបង្គាប់ឱ្យនាំខ្លួន, ១៦ វិច្ឆិកា ២០០៧, C24

[5] កំណត់ហេតុនាំខ្លួនជនសង្ស័យ, ១៩ វិច្ឆិកា ២០០៧, C24/I

[6] កំណត់ហេតុនៃកិច្ចពិភាក្សាដេញដោល ១៩ វិច្ឆិកា ២០០៧, C25

[7] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ១៩ វិច្ឆិកា ២០០៧, C26

សហព្រះរាជអាជ្ញា ស្នើឲ្យឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទ ដោយសំអាងលើមូលហេតុដូចខាងក្រោម: មានហានិភ័យនៃការរត់គេចខ្លួនដោយសារតែជននេះមានលំនៅដ្ឋាននៅក្បែរព្រំដែនថៃ និងឥឡូវប្រឈមមុខនឹងទោសអតិបរិមារជាប់ឃុំឃាំងអស់មួយជីវិត ប្រសិនបើត្រូវចោទប្រកាន់ថាមានទោស ដូច្នេះប្រសិនបើដាក់ឲ្យមានសេរីភាព អាចនឹងបង្កឲ្យមានកំហឹងពីសំណាក់ជនរងគ្រោះ និងសាធារណៈជន ពីព្រោះថា ចាប់តាំងពីពេលដែលការចាប់ខ្លួនត្រូវបានធ្វើឡើង ចំនួននៃពាក្យបណ្តឹងចេះតែកើនឡើងជាលំដាប់ ហើយនឹងបង្កឲ្យមានហានិភ័យដល់សណ្តាប់ធ្នាប់សាធារណៈ ហើយសកម្មភាពនៃការសងសឹកអាចនាំឲ្យមានគ្រោះថ្នាក់ដល់សន្តិសុខផ្ទាល់ខ្លួនជនត្រូវចោទ ដូចអំពើហឹង្សាដែលធ្លាប់កើតមានកាលពីឆ្នាំ១៩៩១ នាពេលដែលជននេះចូលមកភ្នំពេញ វិញ ហើយសាក្សីជាច្រើនគឺជាអតីតៈអ្នកនៅក្រោមបង្គាប់របស់ **ខៀវ សំផន** និងមិនហ៊ានផ្តល់សក្ខីកម្មឡើយក្នុងខណៈដែលជននេះមានសេរីភាព ។ សហព្រះរាជអាជ្ញាគូសបញ្ជាក់ថា **ខៀវ សំផន** គឺជាប្រមុខរដ្ឋនៃរបបមួយដែលទទួលខុសត្រូវលើជនរងគ្រោះ ១,៧ លាននាក់ ហើយវាជាការពិតដែលថាគាត់មិនមែនជាសមាជិកនៃគណៈកម្មាធិការអចិន្ត្រៃយ៍នៃបក្សកុម្មុយនីស្តកម្ពុជា ក៏ប៉ុន្តែគាត់បានចូលរួមក្នុងកិច្ចប្រជុំនោះ និងជននេះមិនធ្លាប់បានប្រកាស ឬ អន្តរាគមន៍ទប់ស្កាត់ឧក្រិដ្ឋកម្មនានាឡើយ[8] ។

**ខៀវ សំផន** នាពេលសវនាការតទល់គ្នាបានជំទាស់នឹងឧក្រិដ្ឋកម្ម ដែលគាត់ត្រូវបានចោទប្រកាន់ ។ **ខៀវ សំផន** បានលើកឡើងថា សហព្រះរាជអាជ្ញារំលឹកពីមុខងារដែលគាត់បានកាន់កាប់ ដែលវាមិនមានលក្ខណៈគ្រប់គ្រាន់ដើម្បីបង្ហាញពីពិរុទ្ធភាព ដែលតាមការពិតគាត់គ្មានអំណាចឡើយក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។ គាត់បានប្រកាសថា ក្នុងនាមជាប្រធាននៃគណៈប្រធានរដ្ឋគាត់គ្រាន់តែមានតួនាទីតំណាងប៉ុណ្ណោះ ហើយគាត់មិនធ្លាប់ជាប្រធានមន្ទីរ៨៧០ឡើយ ហើយគណៈកម្មាធិការមជ្ឈឹមបក្សពុំមានអំណាចក្នុងការសម្រេចទេ ពេលដែលគាត់ចូលរួមប្រជុំ "ដែលមានការពង្រីក" របស់គណៈកម្មាធិការអចិន្ត្រៃយ៍ដែលគាត់មិនមែនជាសមាជិក គឺគ្រាន់តែពិភាក្សាពីបញ្ហាទូទៅប៉ុណ្ណោះ[9] ។ ជាងនេះទៅទៀត **ខៀវ សំផន** លើកឡើងថាលក្ខខ័ណ្ឌនៃការឃុំខ្លួនបណ្តោះអាសន្ន មិនត្រូវបានបំពេញព្រោះថា:

គាត់មិនដែលមានចេតនាក្នុងការរត់គេចខ្លួន ហើយថា ហានិភ័យនៃចលាចលចំពោះសណ្តាប់ធ្នាប់សាធារណៈក៏មិនមានដែរ ដោយគូសបញ្ជាក់ថា ចាប់តាំងពីឆ្នាំ១៩៩៨ ពេលដែលគាត់ចុះចូលជាមួយរដ្ឋាភិបាល គាត់បានរស់នៅក្នុងផ្ទះជាច្រើននៅប៉ៃលិនដោយគ្មានការការពារជាពិសេសឡើយ ហើយព្រឹត្តិការណ៍ដែលគាត់ជារងជនរងគ្រោះនាឆ្នាំ១៩៩១ វាកើតឡើងក្នុងបរិបទពិសេសមួយនៃការអនុវត្តកិច្ចព្រមព្រៀងក្រុងប៉ារីសប៉ុណ្ណោះ[10] ។

---

[8] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌ ៣

[9] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌ ៤

[10] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌ ៤

បញ្ហានៅចំពោះមុខសហចៅក្រមស៊ើបអង្កេតគឺថា (i) អនុលោមតាមវិធាន ៦៣(៣)(ក) តើមានមូលហេតុច្បាស់លាស់ដែលនាំឲ្យជឿជាក់ថា **ខៀវ សំផន** បានប្រព្រឹត្តបទល្មើសដូចដែលបានចោទប្រកាន់ ឬយ៉ាងណា (ii) ថាតើការឃុំខ្លួនបណ្តោះអាសន្នជាវិធានការណ៍ចាំបាច់ដោយគោរពតាមលក្ខខ័ណ្ឌ ដូចដែលមានចែងក្នុងវិធានផ្នែកក្នុងវិធាន៦៣(៣)(ខ) ឬទេ ។

## សេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេត

សហចៅក្រមស៊ើបអង្កេតផ្តល់ហេតុផលដូចខាងក្រោម:

"តាមរយៈឯកសារ និងចម្លើយសាក្សីជាច្រើនដែលមានក្នុងសុំណុំរឿង មានហេតុផលនានាដែលអាចឲ្យជឿជាក់ថា **ខៀវ សំផន** បានប្រព្រឹត្តនូវបទល្មើសដូចដែលបានដាក់បន្ទុកមែន ហើយជាពិសេសក្នុងនាមជាមេដឹកនាំរបស់កម្ពុជាប្រជាធិបតេយ្យ និងជាប្រមុខរដ្ឋ **ខៀវ សំផន** បានអនុវត្តអំណាចជាក់ស្តែងដែលអាចឲ្យមើលឃើញពីខាងក្រៅទាំងក្នុងប្រទេស និងក្រៅប្រទេស [11]។

សហចៅក្រមស៊ើបអង្កេតយល់ឃើញថា លក្ខខ័ណ្ឌនៃវិធាន ៦៣(៣)(ក) ត្រូវបានបំពេញ ។

សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់ថា ការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការណ៍ចាំបាច់ដោយយោងតាមលក្ខខ័ណ្ឌក្នុងវិធាន ៦៣(៣)(ខ) (i), (iv) និង (v) ។ សហចៅក្រមស៊ើបអង្កេតយល់ឃើញជាដំបូងថាការឃុំខ្លួនបណ្តោះអាសន្នគឺជាវិធានការណ៍ចាំបាច់ក្នុងការការពារសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខផ្ទាល់ខ្លួនរបស់ **ខៀវ សំផន** ។

អង្គហេតុទាំងនេះមានលក្ខណៈធ្ងន់ធ្ងរ ទោះជាវាមានរយៈពេល ៣០ឆ្នាំ ក្រោយពេលឧក្រិដ្ឋកម្មកើតឡើងក៏ដោយ ក៏នៅតែបង្កបញ្ហាធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈដដែល ។ ហេតុដូច្នេះវាមិនមែនជាការហួសហេតុពេកទេដែលអះអាងថាក្នុងបរិបទផុយស្រួយនៃសង្គមកម្ពុជាបច្ចុប្បន្ន ការដោះលែងជនត្រូវចោទអាចនឹងបង្កឲ្យមានការសំដែងនូវការមិនពេញចិត្តដែលអាចបង្កឲ្យមានអំពើហិង្សា ឬអាចប៉ះពាល់ដល់សន្តិសុខផ្ទាល់ខ្លួនរបស់ជនត្រូវចោទ ។ម្យ៉ាងវិញទៀត ស្ថានភាពមិនអាចមើលឃើញជាក់លាក់ដូចគ្នាទេ រវាងពេលមុនការចោទប្រកាន់ និងក្រោយពេលចោទប្រកាន់ជាផ្លូវការនោះ[12] ។

សហចៅក្រមស៊ើបអង្កេតបានបញ្ជាក់បន្ថែមទៀតថា ប្រសិនបើ **ខៀវ សំផន** ត្រូវបានដាក់ឲ្យមានសេរីភាព វាអាចនាំឲ្យមានការព្រួយបារម្ភដែលថា ជននេះអាចនឹងធ្វើការជ្រៀតជ្រែកលើសាក្សី ដោយសារថាគាត់អាចមើលសំណុំរឿងទាំងមូល និង ឈ្មោះរបស់សាក្សីបាន[13] ។

---

[11] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌ ៥

[12] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌ ៦

[13] ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, កថាខណ្ឌ ៧

ចុងក្រោយសហចៅក្រមស៊ើបអង្កេតលើកឡើងថា មិនមានវិធានការណ៍ត្រួតពិនិត្យតាមផ្លូវតុលាការណាមួយដែលមានលក្ខណៈតឹងរឹងគ្រប់គ្រាន់ ដើម្បីបំពេញតាមលក្ខខ័ណ្ឌទាំងឡាយដូចមានចែងក្នុងវិធាន ៦៣(៣) ហើយការឃុំខ្លួនគឺជាមធ្យោបាយតែមួយគត់ដែលអាចសម្រេចគោលបំណងនេះ ។

**ឃ) បណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន**

នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៧ សហមេធាវីរបស់ **ខៀវ សំផន** បានដាក់សេចក្តីជូនដំណឹងអំពីការប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន និងដាក់សារណាគាំទ្របណ្តឹងឧទ្ធរណ៍ ចូលមកអង្គបុរេជំនុំជម្រះនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ ។

សហមេធាវីស្នើសុំឲ្យអង្គបុរេជំនុំជម្រះសម្រេច និងប្រកាសថា **ខៀវ សំផន** មិនមែនជាជនត្រូវចោទតទៅទៀតឡើយ ព្រោះថាលោក **ខៀវ សំផន** ត្រូវបានទទួលស្គាល់ថាពុំមានអំណាចជាក់ស្តែងសម្រាប់បង្គាប់បញ្ជាអ្នកណា ឬអង្គភាពចាត់តាំងលំដាប់ថ្នាក់ណាមួយបានឡើយ ហើយថា គាត់គ្រាន់តែជាប្រមុខរដ្ឋដែលមានតែឈ្មោះប៉ុណ្ណោះ[14] និងស្នើសុំឲ្យបដិសេធដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧ ដោយមូលហេតុគ្មានពិរុទ្ធភាពមកលើរូបលោក **ខៀវ សំផន** ។ សហមេធាវីមិនបានធ្វើសេចក្តីសន្និដ្ឋានក្នុងសារណាបណ្តឹងឧទ្ធរណ៍របស់ខ្លួន ទាក់ទងនឹងសេចក្តីសម្រេចឃុំខ្លួនបណ្តោះអាសន្នរបស់សហចៅក្រមស៊ើបអង្កេត ដែលជាវិធានការណ៍ចាំបាច់ជាមួយនឹងខណ្ឌនៃការឃុំខ្លួនដែលមានចែងក្នុងវិធាន ៦៣(៣)(ខ) នៃវិធានផ្ទៃក្នុង ។

**ង) សេចក្តីសន្និដ្ឋានតបរបស់សហព្រះរាជអាជ្ញា**

សេចក្តីសន្និដ្ឋានតបទៅនឹងបណ្តឹងឧទ្ធរណ៍ ត្រូវបានធ្វើឡើងដោយសហព្រះរាជអាជ្ញា និងដាក់ជូនមកអង្គបុរេជំនុំជម្រះនៅថ្ងៃទី២ ខែកុម្ភៈ ឆ្នាំ២០០៨ ។ សហព្រះរាជអាជ្ញាលើកឡើងថា គួរតែបដិសេធបណ្តឹងឧទ្ធរណ៍ចោល ហើយដំកល់ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ព្រោះថាលក្ខខ័ណ្ឌតាមវិធាន៦៣(៣) នៃវិធានផ្ទៃក្នុងត្រូវបានបំពេញ ។

**ច) សេចក្តីសន្និដ្ឋានតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី**

នៅថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០០៨ អង្គបុរេជំនុំជម្រះអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីដាក់សេចក្តីសន្និដ្ឋានតបទៅនឹងបណ្តឹងឧទ្ធរណ៍របស់ជនត្រូវចោទ ក្នុងរយៈពេល ១៥ថ្ងៃ ។ ការពន្យាពេលត្រូវបានផ្តល់ឲ្យរហូតដល់ថ្ងៃ ១៧ ខែមេសា ឆ្នាំ២០០៨ ។ នៅថ្ងៃ ១៧ ខែមេសា ឆ្នាំ២០០៨ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានដាក់ជូនមកនូវសេចក្តីសន្និដ្ឋានតបរួមគ្នាមួយ តបទៅនឹងបណ្តឹងរបស់ ខៀវ សំផន ជំទាស់នឹងដីកាសម្រេចឃុំខ្លួន

[14] សារណាបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន, ១៩ វិច្ឆិកា ២០០៧ , ២១ ធ្នូ ២០០៧, C26/I/3 (សារណាបណ្តឹងឧទ្ធរណ៍) ទំព័រ ១២

បណ្ដោះអាសន្ន[15] ។ ក្នុងសេចក្ដីសន្និដ្ឋាននេះ សហមេធាវីស្នើសុំឱ្យបដិសេធបណ្ដឹងឧទ្ធរណ៍ ហើយគាំទ្រជំហររបស់សហព្រះរាជអាជ្ញា ។

## II. ការពិនិត្យសំណុំរឿងដោយចៅក្រមស៊ើបសួរ

## ក) ការលើកឡើងរបស់មេធាវី ខៀវ សំផន

### ១) ការចោទប្រកាន់រួម

សហមេធាវីលើកឡើងថា សហព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ជារួមប្រឆាំងនឹងជនសង្ស័យមួយចំនួនជា "ការចោទប្រកាន់ទទេៗ មិនចំពោះអ្នកណាពិតប្រាកដ និងជាទូទៅ"[16] គឺគ្មានសុពលភាពតាមផ្លូវច្បាប់ ។

សហមេធាវីលើកឡើងថា ការចោទប្រកាន់សហព្រះរាជអាជ្ញាគឺ "ជាការចោទប្រកាន់រួមចំពោះមេដឹកនាំបក្សកុម្មុយនីស្តកម្ពុជា"[17] ហើយលើកឡើងថា បក្សកុម្មុយនីស្តកម្ពុជាមិនមែនជាបក្សខុសច្បាប់ទេក្នុងសម័យកាលនោះ ។

សហមេធាវីលើកឡើងបន្ថែមទៀតថា សហព្រះរាជអាជ្ញា "មិនមានភាពច្បាស់លាស់ក្នុងការចោទប្រកាន់របស់ខ្លួនទាក់ទងនឹងការកកើតនៃផែនការឧក្រិដ្ឋកម្មរួម"[18] ។ សហមេធាវីលើកឡើងថា "គោលការណ៍ទូទៅនៃនីតិព្រហ្មទណ្ឌមិនអនុញ្ញាតការចោទប្រកាន់ដែលឈរលើ វិមតិសង្ស័យទេ"[19] ហើយ "ស្នើសុំឱ្យបដិសេធទុកជាអសាបង់ នូវចំនុចចោទប្រកាន់ដែលថាមានផែនការឧក្រិដ្ឋកម្មរួម"[20] យោងតាមមាត្រា ៣៨ វាក្យខ័ណ្ឌទី៦ នៃរដ្ឋធម្មនុញ្ញ ព្រះរាជាណាចក្រកម្ពុជា ។ "សហមេធាវីការពាក្តីស្នើសុំឱ្យបដិសេធទំរង់រួមគ្នានៃការចោទប្រកាន់លើលោក **ខៀវ សំផន**"[21] ។

ចុងក្រោយសហមេធាវីលើកឡើងថា "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មិនមែនជាតុលាការនយោបាយដែលបង្កើតឡើងសម្រាប់វិនិច្ឆ័យទោសគណបក្សនយោបាយ និង របបនយោបាយឡើយ" ហើយថា "យុត្តាធិការរបស់តុលាការនេះ មានព្រំដែនកំណត់ត្រឹមកាត់ទោសបុគ្គល មិនមែនកាត់ទោសស្ថាប័នទេ"[22] ។ សហមេធាវីលើកឡើងថា ក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរ "វាមានការច្របូកច្របល់ដែលមិនអាចទទួលយកបាន

---

[15] សេចក្ដីសន្និដ្ឋានតបរបស់សហមេធាវីដើមបណ្ដឹងរដ្ឋប្បវេណីតបទៅនឹងបណ្ដឹងរបស់ ខៀវ សំផន ជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្នចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ ២០០៨ (C26/I/21 "សេចក្ដីសន្និដ្ឋានតបរបស់ដើមបណ្ដឹងរដ្ឋប្បវេណី)

[16] សារណាបណ្ដឹងឧទ្ធរណ៍ ទំព័រ ២៥

[17] សារណាបណ្ដឹងឧទ្ធរណ៍ ទំព័រ ២៤

[18] សារណាបណ្ដឹងឧទ្ធរណ៍ ទំព័រ ២៨

[19] សារណាបណ្ដឹងឧទ្ធរណ៍ ទំព័រ ២៨

[20] សារណាបណ្ដឹងឧទ្ធរណ៍ ទំព័រ ២៩

[21] សារណាបណ្ដឹងឧទ្ធរណ៍ ទំព័រ ៣០

[22] សារណាបណ្ដឹងឧទ្ធរណ៍ ទំព័រ ៣១

រវាងអំពើប្រព្រឹត្តដោយបក្សកុម្មុយនីស្តកម្ពុជា និងស្ថាប័នរដ្ឋកម្ពុជាប្រជាធិបតេយ្យ ជាមួយនឹងអំពើផ្ទាល់ខ្លួនម្នាក់ៗនៃជនសង្ស័យទាំង ៥រូប"[23] ។ យោងតាមមាត្រា ២៩(ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា សហមេធាវីលើកឡើងថា "អំពើទាំងឡាយដែលផ្តាច់ចេញពីអង្គការ និងអាចទំលាក់ទៅលើជនសង្ស័យម្នាក់ៗ តែត្រូវកំណត់អត្តសញ្ញាណឲ្យបានច្បាស់លាស់"[24] ហើយស្នើសុំឲ្យអង្គបុរេជំនុំជម្រះបដិសេធរាល់ការចោទប្រកាន់រួមគ្នាដែលផ្ទុយនឹងស្មារតី និងអត្ថបទនៃមាត្រា ២៩ (ថ្មី)"[25] ។

## ២) អវត្តមាននៃកំហុសផ្ទាល់ខ្លួន

សហមេធាវីលើកឡើងថា "ព័ត៌មានដែលមានបង្ហាញក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ សុទ្ធតែឈរលើមូលដ្ឋាននៃឯកសារ និងសេចក្តីថ្លែងនានាមិនត្រឹមត្រូវ ហើយភាគច្រើនខុស"[26] ។ សហមេធាវីស្នើសុំឲ្យអង្គបុរេជំនុំជម្រះធ្វើការចាត់តាំង "អ្នកជំនាញអន្តរជាតិដែលឯករាជ្យ ល្បីឈ្មោះ និងមានសមត្ថភាព ដើម្បីធ្វើកោសលវិច័យលើយថាភាព និង នីត្យានុកូលភាព" នៃឯកសារនិងសេចក្តីថ្លែងទាំងអស់ដែលយកមកធ្វើជាមូលដ្ឋានដើម្បីចោទប្រកាន់លើ **ខៀវ សំផន**"[27] ។

សហមេធាវីលើកឡើងបន្ថែមទៀតថា កំហុសបុគ្គលមិនអាចត្រូវទំលាក់មកលើ **ខៀវ សំផន** ទេ ព្រោះថាគាត់ពុំមាន "អំណាចជាក់ស្តែង និងមានប្រសិទ្ធភាព"[28] ក្នុងរបបកម្ពុជាប្រជាធិបតេយ្យឡើយ ។ សហមេធាវីលើកឡើងថា:

(១) "ដោយដើមកំណើតត្រកូលរបស់គាត់ **ខៀវ សំផន** ដែលត្រូវបាន ប៉ុល ពត វិនិច្ឆ័យថាជាកូនសក្តិភូមិរលំរលាយ មិនអាចកាន់កាប់អំណាចជាក់ស្តែង និងមានប្រសិទ្ធិភាពណាមួយបានឡើយ"[29] ។

(២) "មុខតំណែងជាប្រធានគណៈប្រធានរដ្ឋ គឺជាប្រមុខរដ្ឋ គ្រាន់តែជាមុខតំណែងកិត្តិយស និងសម្រាប់ពិធីការប៉ុណ្ណោះ គ្មានអំណាចជាក់ស្តែង និង មានប្រសិទ្ធិភាពលើស្ថាប័នរដ្ឋ ឬ បុគ្គលណាម្នាក់ឡើយ"[30] ។

(៣) **ខៀវ សំផន** មិនដែលត្រូវបានតែងតាំង ឬ ត្រូវបានបោះឆ្នោតឲ្យធ្វើជា "ប្រធានមន្ទី ៨៧០"[31] ឡើយ គាត់គ្រាន់តែជាសមាជិកធម្មតានៃមន្ទីនេះ ហើយមានភារកិច្ចធ្វើបញ្ជីតម្លៃទំនិញ ធ្វើការចែកចាយឥវ៉ាន់អង្គការ និង រក្សាទំនាក់ទំនងល្អជាមួយនឹងសម្តេចព្រះនរោត្តមសីហនុ ។

---

[23] សារណាបណ្តឹងឧទ្ធរណ៍ ទំព័រ ៣២
[24] សារណាបណ្តឹងឧទ្ធរណ៍ ទំព័រ ៣៤
[25] សារណាបណ្តឹងឧទ្ធរណ៍ ទំព័រ ៣៧
[26] សារណាបណ្តឹងឧទ្ធរណ៍ ទំព័រ ៤០
[27] សារណាបណ្តឹងឧទ្ធរណ៍ ទំព័រ ៤០ និង ៤១
[28] សារណាបណ្តឹងឧទ្ធរណ៍ ទំព័រ ៣៩
[29] សារណាបណ្តឹងឧទ្ធរណ៍ ទំព័រ ៤២
[30] សារណាបណ្តឹងឧទ្ធរណ៍ ទំព័រ ៤៥

(៤) **ខៀវ សំផន** ពុំមានទំនាក់ទំនងជាមួយនឹងមន្ទីរ ស២១ ឡើយ ហើយពុំទទួលបន្ទុកខាងអប់រំនយោបាយដល់ពួកអ្នកដែលវិលត្រឡប់ពីការនិរទេសខ្លួនទេ។

(៥) ដោយសារវិធាននៃការសម្ងាត់នៃបក្សកម្ពុជាប្រជាធិបតេយ្យ **ខៀវ សំផន** " ពុំបានដឹងអ្វីច្រើនទេ ស្ទើរតែរឿងដែលកើតឡើងជុំវិញខ្លួនគាត់"[32] ។

យោងតាមមាត្រា៣៨ វាក្យខ័ណ្ឌ៦ នៃរដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា សហមេធាវីបានស្នើសុំឱ្យអង្គបុរេជំនុំជម្រះប្រកាសថា **ខៀវ សំផន** ពុំមានជាប់ពិរុទ្ធក្នុងឧក្រិដ្ឋកម្មដែលគាត់ត្រូវបានចោទប្រកាន់នោះទេ ។

**ខ) ការលើកឡើងរបស់សហព្រះរាជអាជ្ញា**

**បញ្ហាបឋម**

**១) ការស្នើសុំដីកាបដិសេធដោយសហមេធាវី**

ឆ្លើយតបទៅនឹងការស្នើសុំរបស់សហមេធាវី ដែលសុំឱ្យអង្គបុរេជំនុំជម្រះបដិសេធចោលសំណុំរឿងទាំងមូលប្រឆាំងនឹង **ខៀវ សំផន** ដោយហេតុថាពុំមានភស្តុតាងគ្រប់គ្រាន់ សហព្រះរាជអាជ្ញាលើកឡើងថា "នៅក្នុងដំណាក់កាលដំបូងនៃកិច្ចស៊ើបសួរបែបនេះ គឺគ្មានមូលដ្ឋានច្បាប់ដើម្បីបដិសេធសំណុំរឿងនេះចោល ពីសំណាក់សហចៅក្រមស៊ើបអង្កេត ឬពីសំណាក់អង្គបុរេជំនុំជម្រះឡើយ"[33] ។ សហព្រះរាជអាជ្ញាលើកឡើងបន្ថែមទៀតថា "បទដ្ឋានពេញលេញនៃភស្តុតាងពិរុទ្ធភាពហួសពីវិមតិសង្ស័យ គឺត្រូវអនុវត្តបានតែនៅក្នុងការបញ្ចប់សវនាការតែប៉ុណ្ណោះ" ហើយមានតែក្នុងដំណាក់កាលនៃនីតិវិធីចុងក្រោយនេះទេ "ទើបភស្តុតាងត្រូវបានវាយតម្លៃពេញ ហើយផលប្រយោជន៍នៃវិមតិសង្ស័យត្រូវបានទៅលើជនជាប់ចោទ" [34]។

**២) ការស្នើសុំរបស់មេធាវីក្នុងឱ្យមានការចាត់តាំងអ្នកជំនាញ**

សហព្រះរាជអាជ្ញាលើកឡើងថា ការស្នើសុំរបស់មេធាវីដែលសុំឱ្យមានការចាត់តាំងអ្នកជំនាញគួរតែបដិសេធចោលព្រោះថា "វាមិនបានលើកឡើងឱ្យចំៗថា តើឯកសារ ឬសេចក្តីថ្លែងណាមួយដែលចោទថាពុំមានលក្ខណៈត្រឹមត្រូវ ហើយវាក៏មិនមានទទ្បីករណ៍គាំទ្រ និងមិនបានបញ្ជាក់ច្បាស់ថាតើការវិភាគប្រភេទណាដែលគួរតែត្រូវបានធ្វើឡើង"[35] ។ សហព្រះរាជអាជ្ញាបន្ថែមទៀតថា "ប្រសិនបើពាក្យថា "នីត្យានុកូលភាព" មេធាវី

---

[31] សារណាបណ្តឹងឧទ្ធរណ៍ ទំព័រ ៥១

[32] សារណាបណ្តឹងឧទ្ធរណ៍ ទំព័រ ៥៦

[33] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន ដែលជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ១៩ វិច្ឆិកា ២០០៧, ៦ កុម្ភៈ ២០០៨, C26/I/9 (ចម្លើយតបរបស់សហព្រះរាជអាជ្ញា) កថាខណ្ឌ៦

[34] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៩

[35] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២០

ការពារក្តីប្រើសំដៅទៅលើភាពដែលអាចទទួលយកបាន ភាពជាប់ពាក់ព័ន្ធ ឬ ទម្ងន់នៃភស្តុតាង បញ្ហាទាំងនេះ គឺជាសមត្ថកិច្ច ផ្តាច់មុខរបស់ចៅក្រមនៃអង្គជំនុំជម្រះវិសាមញ្ញ"[36] ។

**ការឃុំខ្លួនបណ្តោះអាសន្ន**

១). **មានមូលហេតុដែលត្រូវបានរកឃើញនិងជឿជាក់ច្បាស់ថា ជននោះធ្លាប់បានប្រព្រឹត្ត បទល្មើសមួយ ឬ ច្រើន ដូចមានចែងក្នុងដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ( វិធាន ៦៣(៣)(ក) )**

សហព្រះរាជអាជ្ញាលើកឡើងថា វិធាន ៦៣(៣)(ក) តម្រូវឲ្យមាន "ភស្តុតាងបង្ហាញថា ជនត្រូវចោទ អាចនឹងទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌចំពោះបទឧក្រិដ្ឋណាមួយ ហើយភស្តុតាងនោះមានលក្ខណៈស៊ីសង្វាក់គ្នា យ៉ាងសំខាន់ ហើយភស្តុតាងនោះតាមទិដ្ឋភាពខាងក្រៅគឺនាំឲ្យមានការជឿជាក់"[37] ។

សហព្រះរាជអាជ្ញាបានលើកឡើងថា "នៅក្នុងកន្លែងជាច្រើននៃបណ្តឹងឧទ្ធរណ៍ មេធាវីការពារក្តីបានយល់ស្របថា បទឧក្រិដ្ឋនានាពិតជាបានប្រព្រឹត្តមែន ។ ការទាញហេតុផលរបស់មេធាវី គឺតវ៉ាជំទាស់ចំពោះការដែលថា **ខៀវ សំផន** ទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ"[38] ។ ក្នុងការឆ្លើយតបទៅនឹងការអះអាងរបស់មេធាវីដែលថា **ខៀវ សំផន** ត្រូវបានចោទប្រកាន់ជាសម្ភូហភាព សហព្រះរាជអាជ្ញា បញ្ជាក់ម្តងទៀតថា **ខៀវ សំផន** មានការទទួលខុសត្រូវដោយផ្ទាល់ចំពោះបទល្មើសដែលបានលើកឡើងក្នុងកថាខ័ណ្ឌ ១២២ ក-ឃ នៃដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ។ យោងតាមសហព្រះរាជអាជ្ញា " **ខៀវ សំផន** កាន់ដំណែងខ្ពស់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់បានចូលរួមក្នុងកិច្ចប្រជុំសំខាន់ៗ ដែលធ្វើការពិភាក្សា ត្រួតពិនិត្យ និងបង្កើត គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា និងគោលនយោបាយរបស់កម្ពុជាប្រជាធិបតេយ្យ ។ គាត់គឺជាប្រធានមន្ទីរ ៨៧០ ដែលជាមន្ទីរដ៏សំខាន់ និងសំងាត់មួយនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ គាត់បានថ្លែងសុន្ទរកថាជាលក្ខណៈជាតិ និងអន្តរជាតិផ្តល់ការគាំទ្រ និងភាពស្របច្បាប់ ដល់របបនេះ"[39] ។

សហព្រះរាជអាជ្ញា បានទាញចំណាប់អារម្មណ៍បន្ថែមទៀតដល់អង្គបុរេជំនុំជម្រះទៅលើការបង្ហាញដែលក្នុងគំនិតនេះ "បង្ហាញពីការដឹងឮ និងការចូលរួមដោយផ្ទាល់របស់ **ខៀវ សំផន**"[40] ទៅក្នុងបទឧក្រិដ្ឋកម្ម ។ ដោយពិចារណាថា ការស៊ើបអង្កេតត្រូវរក្សាការសម្ងាត់ក្នុងដំណាក់កាលនៃនីតិវិធីនេះ ការលើកឡើងរបស់សហព្រះរាជអាជ្ញាទាក់ទងនឹងបញ្ហានេះ ត្រូវបានដកចេញពីរបាយការណ៍សម្រាប់ផ្សាយជាសាធារណៈ ។

---

[36] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៤១

[37] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ២៥

[38] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៣

[39] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៨

[40] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣៩

## ***២. ការឃុំខ្លួនបណ្តោះអាសន្នជាវិធានការណ៍ចាំបាច់ ( វិធានផ្នែកក្នុងវិធាន ៦៣(៣)(ខ) )***

សហព្រះរាជអាជ្ញាជាដំបូងគូសបញ្ជាក់ថា នៅពេលសវនាការតទល់ “មេធាវីការពារក្តី ធ្វើសេចក្តីសន្និដ្ឋានដោយផ្អែកលើហេតុផលផ្ទាល់ខ្លួន ចំពោះការឃុំខ្លួនបណ្តោះអាសន្ន” ហើយ “គ្មានសេចក្តីសន្និដ្ឋានណាមួយត្រូវបានពន្យល់ឲ្យស៊ីជំរៅនៅក្នុងបណ្តឹងឧទ្ធរណ៍របស់មេធាវីការពារក្តីឡើយ”[41] ។

សហព្រះរាជអាជ្ញាលើកឡើងថា យោងតាមយុត្តិសាស្ត្រអន្តរជាតិ “បន្ទុកនៃភស្តុតាងធ្លាក់ទៅលើជនត្រូវចោទដើម្បីបង្ហាញឲ្យឃើញថា កត្តានានាដើម្បីបង្ហាញហេតុផលការឃុំខ្លួនបណ្តោះអាសន្នពិតជាមិនមានអត្ថិភាពឡើយ” [42]។

***វិធានការណ៍ចាំបាច់ដើម្បីការពារជនត្រូវចោទក្នុងការដាក់ការគាបសង្កត់ទៅលើសាក្សី ឬ ជនរងគ្រោះ ឬ ការពារការឃុបឃិតគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត នៃបទឧក្រិដ្ឋដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក***
***<u>( វិធានផ្នែកក្នុងវិធាន ៦៣(៣)(ខ) (i)</u>***

សហព្រះរាជអាជ្ញាលើកឡើងថា ផ្ទុយពីការអះអាងរបស់ **ខៀវ សំផន** “មានភស្តុតាងដែលអាចជឿជាក់បាន ដែលថាជនត្រូវចោទមានចំនួនបុគ្គលិកច្បាស់លាស់ដែលនៅក្រោមការបង្គាប់បញ្ជារបស់គាត់នៅមន្ទីរ៨៧០” ។ សហព្រះរាជអាជ្ញាលើកឡើងថាបន្ថែមទៀតថា **ខៀវ សំផន** “ធ្លាប់ជាមនុស្សម្នាក់ដែលមានអំណាច និងឥទ្ធិពលនៅក្នុងប្រទេសកម្ពុជាសឹងតែក្នុងមួយជីវិតពេញវ័យរបស់គាត់”[43] ហើយគាត់ “បន្តទទួលបាននូវការគាំទ្រដ៏មានប្រជាប្រិយភាពនៅក្នុងតំបន់ប៉ៃលិននៃប្រទេសកម្ពុជា ដែលគេបានពិពណ៌នាជាប្រពៃណីថាជាទីតាំងដ៏រឹងមាំរបស់ខ្មែរក្រហម”[44] ។ យោងតាមសហព្រះរាជអាជ្ញា “ឥទ្ធិពលរបស់ **ខៀវ សំផន** ជាពិសេស នៅតែមាននៅឡើយ និង លាតសន្ធឹងទៅលើអ្នកដែលបានឃើញ និង អ្នកដែលជាជនរងគ្រោះនៃឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តក្នុងរបបកម្ពុជាប្រជាធិបតេយ្យ”[45] ។

**សហព្រះរាជអាជ្ញាលើកឡើងថា**

**ខៀវ សំផន** បានធ្វើការព្រមានជាសាធារណៈអំពី “ការសងសឹកតបវិញ” ប្រសិនបើគាត់ត្រូវបានគេនាំខ្លួនទៅកាត់ទោស ។ ការព្រមាននេះមិនកំណត់ថាសងសឹកតបចំពោះនណានោះទេ ប៉ុន្តែដោយសារតែគាត់គឺជាអតីតៈអ្នកនយោបាយមួយរូបដែលមានឥទ្ធិពល ការណ៍នេះត្រូវបានចាត់ទុកថាជាការគំរាមកំហែងដោយប្រយោលចំពោះអ្នកទាំងឡាយណាដែលនឹងត្រូវចូលរួមក្នុងដំណើរការកាត់សេចក្តី ជាពិសេសគឺសាក្សី និង ជន

[41] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ១៥

[42] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៣១

[43] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៥

[44] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៦

[45] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៦

រងគ្រោះ ។ បញ្ហានេះគួតែត្រូវបានគេមើលឃើញ ដោយផ្អែកលើសភាពការណ៍ទូទៅនៅក្នុងប្រទេសដែលមិនមានគំរោងផែនការណ៍សម្រាប់ការការពារសាក្សី ហើយដែលមានអត្រានៃអំពើឧក្រិដ្ឋកម្មដោយហិង្សាក្នុងកំរិតខ្ពស់នៅឡើយ និងសំបូរដោយអាវុធជាតិផ្ទុះដែលងាយរកបាន[46] ។

សហព្រះរាជអាជ្ញាបន្ថែមថា "មានការភ័យខ្លាចយ៉ាងទូលំទូលាយក្នុងការមកឆ្លើយបំភ្លឺនៅចំពោះមុខ អ.វ.ត.ក ដោយផ្អែកលើការព្រួយបារម្ភចំពោះការសងសឹក និងការបំភិតបំភ័យ"[47] ។

***វិធានការណ៍ចាំបាច់ដើម្បីធានានូវការបង្ហាញខ្លួនរបស់ជនត្រូវចោទពេលសវនាការ (វិធានផ្ទៃក្នុងវិធាន ៦៣(៣)(ខ)(iii) )***

សហព្រះរាជអាជ្ញាលើកឡើងថា "លទ្ធភាពក្នុងការដែលត្រូវកាត់ឲ្យជាប់ទោសក្នុងរយៈពេលវែង ផ្តល់ការលើកទឹកចិត្តយ៉ាងខ្លាំងដល់ជនត្រូវចោទឲ្យរត់គេចខ្លួន"[48] ។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា "សុន្ទរកថាជាសាធារណៈរបស់ **ខៀវ សំផន** បង្ហាញឲ្យឃើញថាគាត់ពុំមានជំនឿទៅលើយុត្តិធម៌ដែលនឹងផ្តល់ឲ្យដោយ អ.វ.ត.ក ទេ" ប្រការនេះតំណាងឲ្យការជំរុញទឹកចិត្តបន្ថែមទៀតដើម្បីឲ្យគាត់រត់គេចខ្លួន"[49] ។

សហព្រះរាជអាជ្ញាលើកឡើងថា **ខៀវ សំផន** មានមធ្យោបាយសេដ្ឋកិច្ចដើម្បីរត់គេចខ្លួន ដោយសារគាត់ "គ្រប់គ្រង និងរស់នៅក្នុងផ្ទះនៅតំបន់ប៉ៃលិននៃប្រទេសកម្ពុជា ដែលកៀកនឹងព្រំដែនប្រទេសថៃ"[50] ។ គេជឿថាគ្រួសាររបស់គាត់មានផ្ទះច្រើន រាប់បញ្ចូលទាំងផ្ទះនៅប៉ៃលិន នៅជិតអន្លង់វែង និងនៅក្នុងទីក្រុងភ្នំពេញ"[51] ។ សហព្រះរាជអាជ្ញាបន្ថែមថា "**ខៀវ សំផន** ក៏មានអាជីវកម្មបក្សីផងដែរ"[52] ។ សហព្រះរាជអាជ្ញាក៏បានលើកឡើងផងដែរថា "ទោះបីជាគាត់បដិសេធក្តី ក៏មានភាពអាចកើតឡើងយ៉ាងខ្ពស់ថា **ខៀវ សំផន** មានលិខិតឆ្លងដែន"[53] ហើយខ្សែរយៈទាក់ទង និងទំនាក់ទំនងរបស់គាត់នៅក្នុងប្រទេសថៃ និង ប្រទេសចិន អាចជាជំនួយយ៉ាងច្រើនដល់គាត់ប្រសិនបើគាត់ស្វែងរកការគេចខ្លួនពីយុត្តាធិការរបស់ អ.វ.ត.ក"[54] ។

***វិធានការណ៍ចាំបាច់ដើម្បីការការពារសន្តិសុខផ្ទាល់ខ្លួនរបស់ជនត្រូវចោទ (វិធានផ្ទៃក្នុងវិធាន ៦៣(៣) (ខ)(iv)***

---

[46] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៧

[47] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៥៨

[48] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦០

[49] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៥

[50] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦២

[51] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៣

[52] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦២

[53] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៣

[54] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៤

សហព្រះរាជអាជ្ញាលើកឡើងថា "ការចាប់ខ្លួនរបស់ **ខៀវ សំផន** ដែលមានការផ្សព្វផ្សាយឯកសារជាសាធារណៈ មានន័យថាប្រសិនបើគាត់ត្រូវបានដោះលែង នោះគាត់មិនទទួលបាននូវការការពារដូចមុនឡើយ[55] ។ យោងតាមសហព្រះរាជអាជ្ញា "ការចាប់អារម្មណ៍ដែលកាន់តែកើនឡើងរបស់បណ្ដាញសារព័ត៌មាន ទាក់ទងនឹងការចាប់ខ្លួន **ខៀវ សំផន** និងការដឹងឮជាសាធារណៈកាន់តែទូលាយឡើងថែមទៀតអំពីការចោទប្រកាន់ប្រឆាំងនឹងរូបគាត់ ជាការបង្កឲ្យមានគ្រោះថ្នាក់យ៉ាងពិតប្រាកដដល់សុវត្ថិភាពរបស់គាត់"[56] ។ សហព្រះរាជអាជ្ញាចង្អុលបង្ហាញថា "គ្រោះថ្នាក់ដែលកើនឡើងអំពី "ការវាយប្រហារដើម្បីសងសឹក" អាចត្រូវបានបង្ហាញជាភស្តុតាងដូចការពីពេលបើកសវនាការជាសាធារណៈលើបណ្ដឹងឧទ្ធរណ៍របស់ ឌុច ដែលជំទាស់នឹងការឃុំខ្លួនបណ្ដោះអាសន្ន ពីថ្ងៃ ទី២១ និង ២២ ខែវិច្ឆិកា ឆ្នាំ២០០៧" ដែលត្រូវបានគេរាយការណ៍ឲ្យដឹងថា សាធារណជនជាច្រើនដែលចូលរួមក្នុងសវនាការ មានការលំបាកក្នុងការទប់ចិត្តមិនឲ្យមានអំពើហិង្សាដែលអាចកើតឡើងដោយឯកឯងពេលដែលឃើញ ឌុច ស្ថិតនៅក្នុងចម្ងាយយ៉ាងជិតបង្កើយបែបនេះ"[57] ។

សហព្រះរាជអាជ្ញាលើកឡើងថា "**ខៀវ សំផន** ត្រូវបានវាយប្រហារមកលើរូបរាងកាយពេលដែលគាត់បង្ហាញខ្លួនជាលើកទីមួយនៅទីក្រុងភ្នំពេញ ចាប់តាំងពីរបបកម្ពុជាប្រជាធិបតេយ្យដួលរលំមក" ហើយ "ការកន្លងទៅនៃពេលវេលា មិនបានធ្វើឲ្យការទាក់ទងនឹងការគំរាមកំហែងទាំងនេះចំពោះជនត្រូវចោទថយចុះនោះទេ"[58] ។ យោងតាមសហព្រះរាជអាជ្ញា "សាធារណជនទូទៅកំពុងចាប់ផ្ដើមជឿជាក់ថា និទណ្ឌភាពបានឈានដល់ទីបញ្ចប់ហើយ" ហើយការដោះលែង **ខៀវ សំផន** ចំពេលនេះអាច "ជាការងាយនឹងបញ្ឆេះកំហឹងនៅក្នុងផ្នែកខ្លះនៃសហគមន៍ឲ្យធ្វើការសងសឹកលើរូបគាត់វិញ"[59] ។

### *វិធានការណ៍ចាំបាច់ដើម្បីរក្សាសណ្ដាប់ធ្នាប់សាធារណៈ (វិធានផ្ទៃក្នុង ៦៣(៣)(ខ)(v) )*

សហព្រះរាជអាជ្ញាលើកឡើងថាដោយសារ "នីតិវិធីនៅចំពោះមុខ អ.វ.ត.ក គឺជាឱកាសលើកទីមួយ ហើយដែលជនសង្ស័យទាំងឡាយកំពុងត្រូវបានធ្វើការកាត់ទោសអំពីបទឧក្រិដ្ឋកម្មផ្សេងៗ ដែលបានប្រព្រឹត្តក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យដែលក្នុងពេលនោះមានប្រជាជនកម្ពុជាចំនួន១,៧លាននាក់ ត្រូវបានគេសម្លាប់" ការដោះលែង **ខៀវ សំផន** ជាបណ្ដោះអាសន្នអាច "បណ្ដាលឲ្យមានហានិភ័យដល់សង្គមកម្ពុជា តាមរយៈការលេចឡើងជាថ្មីនូវការព្រួយបារម្ភផ្សេងៗ និងផលវិបាកជាអវិជ្ជមានផ្សេងៗដល់សង្គមកម្ពុជា"[60] ។

---

[55] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៧

[56] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៨

[57] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៨

[58] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៩

[59] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៦៩

[60] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧០

សហព្រះរាជអាជ្ញាគូសបញ្ជាក់ថា "ការគាំទ្រអតីតមេដឹកនាំរបស់ខ្មែរក្រហមនៅតែមាននៅឡើយនៅតំបន់ប៉ៃលិន ដែលជាតំបន់ដែលជាទីតាំងដ៏រឹងមាំជាប្រពៃណីរបស់ពួកគេ" ហើយថា "មន្ត្រីរដ្ឋាភិបាលមូលដ្ឋាននៅក្រុងប៉ៃលិនបានថ្លែងការណ៍ជាសាធារណៈថា ការចាប់ខ្លួនជនសង្ស័យទាំងឡាយពីសំណាក់ អ.វ.ត.ក គឺជាការធ្វើឱ្យមានទុក្ខព្រួយនិងរំខានដល់សន្តិភាព"[61] ។ យោងតាមសហព្រះរាជអាជ្ញា "ព្រឹត្តិការណ៍ថ្មីៗ ដូចជាកុប្បកម្មប្រឆាំងថៃក្នុងឆ្នាំ២០០៣ (....) បង្ហាញឱ្យឃើញថាការវាយប្រហារតូចតាចណាមួយមកលើអត្តសញ្ញាណ ឬ ប្រវត្តិសាស្ត្ររបស់កម្ពុជាក៏អាចក្លាយជាការផ្ទុះឡើងដ៏ខ្លាំងផងដែរ"[62] ។

សហព្រះរាជអាជ្ញាបន្ថែមទៀតថា សេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ **ខៀវ សំផន** អំពី "ការសងសឹកតប" ប្រសិនបើគាត់ត្រូវបានគេនាំទៅកាត់ទោស "មានសក្តានុពលក្នុងការធ្វើឱ្យប៉ះពាល់ធ្ងន់ធ្ងរដល់សណ្តាប់ធ្នាប់សាធារណៈ" ក្នុង "បរិបទនៃសង្គមកម្ពុជាដែលមិនអាចព្យាករណ៍ទុកជាមុន និងដែលងាយនឹងប្រែប្រួល"[63] ។

**ការត្រួតពិនិត្យតាមផ្លូវតុលាការ**

សហព្រះរាជអាជ្ញាគូសបញ្ជាក់ថា ក្នុងពេលសវនាការតទល់ **ខៀវ សំផន** "យល់ព្រមស្នាក់នៅក្នុងផ្ទះនៅក្រុងប៉ៃលិន ដែលត្រូវចាត់ទុកថាជាការសន្យារបស់បុគ្គលផ្ទាល់ថាគាត់នឹងគោរពប្រតិបត្តិតាមលក្ខខ័ណ្ឌផ្សេងៗមួយចំនួនដែលបានកំណត់ ប្រសិនបើគាត់ត្រូវបានដោះលែងក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះ"[64] ។ សហព្រះរាជអាជ្ញាលើកឡើងថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តត្រឹមត្រូវដែលមិនផ្តល់ការដោះលែងក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ព្រោះថាការប្រកាសរបស់ **ខៀវ សំផន** ជាការប្រកាសមិនពិតដែលអាចជឿជាក់បាន ហើយពុំមានបញ្ជាក់អំពីផលវិបាកដែលកើតមានក្នុងខណៈដែលគាត់មិនគោរពតាមលក្ខខ័ណ្ឌទាំងអស់នោះ ហើយពុំបានលើកឡើងអំពីការព្រួយបារម្ភ ដែលទាក់ទងនឹងការការពារសន្តិសុខផ្ទាល់ខ្លួនរបស់គាត់ ឬ ការរក្សានូវសណ្តាប់ធ្នាប់សាធារណៈ ។

## គ) ការលើកឡើងរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី

សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីលើកឡើងថា "អនុលោមតាមវិធាន ៦៣(៣)(ក) នៃវិធានផ្ទៃក្នុង ដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្នគឺផ្អែកលើមូលដ្ឋានមានភស្តុតាងគ្រប់គ្រាន់ ហើយមានមូលហេតុដែលត្រូវបានរកឃើញ និងជឿជាក់បានថាជនត្រូវចោទធ្លាប់បានបទល្មើសដូចដែលបានរៀបរាប់ក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[65] ។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងបន្ថែមថា សហចៅក្រមស៊ើបអង្កេត បាន

[61] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧២

[62] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧២

[63] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧៣

[64] ចម្លើយតបរបស់សហព្រះរាជអាជ្ញា កថាខណ្ឌ ៧៦

[65] សេចក្តីសន្និដ្ឋានតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៥

C26/I/24

អនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនត្រូវត្រឹម ហើយពុំបានបង្ហាញឲ្យឃើញនូវមូលដ្ឋានណាមួយដែលមិនសមហេតុផលឡើយ[66] ។ ក្នុងដំណើរការបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សំណើសុំរបស់មេធាវីការពារក្តីដែលស្នើសុំឲ្យបដិសេធសំណុំរឿងចោលដោយសារជនត្រូវចោទមិនមានពិរុទ្ធ មិនមែនជាមូលដ្ឋានសមស្របឡើយក្នុងការជំទាស់នឹងដីកាឃុំខ្លួនបណ្តោះអាសន្ន[67] ។

ភ្នំពេញ ថ្ងៃទី២២ ខែមេសា ឆ្នាំ២០០៨

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម ហួត វុទ្ធី

ចៅក្រម Rowan Downing

[66] សេចក្តីសន្និដ្ឋានតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៥

[67] សេចក្តីសន្និដ្ឋានតបរបស់ដើមបណ្តឹងរដ្ឋប្បវេណី កថាខណ្ឌ ៥